# ក

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៩-០២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៤ តែងតាំងឯកឧត្តម **ចៅ សុខុន** ជាទីប្រឹក្សាឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី ២ នៃព្រឹទ្ធសភា | ៤១៥ |
| ០៩-០២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៥ តែងតាំងឯកឧត្តម **នួន សំភា** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី ២ នៃព្រឹទ្ធសភា | ៤១៦ |
| ១៤-០២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៦ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី | ៤១៧ |


## II-ក្រុមប្រឹក្សាធម្មនុញ្ញ

### សេចក្តីសំរេច


| | | |
|---|---|---|
| ១២-០២-២០០១ | -សេចក្តីសំរេចលេខ ០៤០/០០២/២០០១ កបធ-ច | ៤២៣ |


## III-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ០៩-០២-២០០១ | -អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីការបង្កើតវិទ្យាស្ថានយោធាកម្ពុជា | ៤២៨ |
| ០៩-០២-២០០១ | -អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពីការបង្កើតសង្កាត់កោះរ៉ុង ចំណុះខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ | ៤៣១ |
| ១៣-០២-២០០១ | -អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការតំរង់ទិសអន្តរក្រសួង ដើម្បីដឹកនាំដំណើការ នៃគំរោងការជំនួយបច្ចេកទេសទាក់ទងនឹងគោលនយោបាយពាណិជ្ជកម្ម | ៤៣៣ |
| ១២-០២-២០០១ | -អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៣៧ |
| ១២-០២-២០០១ | -អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ៤៣៨ |
| ១៥-០២-២០០១ | -អនុក្រឹត្យលេខ ៧១ អនក្រ.តត ស្តីពីការដកហូតមុខតំណែងមន្ត្រីរាជការ | ៤៣៩ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១_ ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត ទិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

☆☆☆

- បានទតទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

**ត្រាស់បង្គាប់**

**មាត្រា ១ .-**

តែងតាំងឯកឧត្តម **ចៅ សុខុន** ជាទីប្រឹក្សាឯកឧត្តម **ញ៉ឹក ប៊ុនឆៃ** អនុប្រធានទី ២ ព្រឹទ្ធសភាមាន ឋានៈស្មើ **អនុរដ្ឋលេខាធិការ** ជំនួសឯកឧត្តម **គីម សុខុន** ដែលបានស្នើសុំលាលែង ។

**មាត្រា ២ .-**

ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យ នេះ ។

**មាត្រា ៣ .-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

**ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៥**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

✡✡✡

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម **នួន សំភា** ជាទីប្រឹក្សាឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី ២ នៃព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ជំនួសលោក **ចៅ សុខុន** ។

**មាត្រា ២.-**

លោក **នួន សំភា** ស្ម័គ្រចិត្តបំរើការងារដោយពុំយកប្រាក់បៀវត្ស ។

**មាត្រា ៣.-**

ប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

☆☆☆

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- បានឃើញអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២
- តាមសេចក្តីក្រាបបង្គំស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ត្រាស់បង្គាប់

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះកំណត់ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី មានអក្សរកាត់ថា **ក.ជ.ក.ស** ។ **ក.ជ.ក.ស** ជាយន្តការសំរបសំរួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល លើបញ្ហាដែលទាក់ទងដល់ការលើកកំពស់ស្ថានភាព តួនាទីរបស់ស្ត្រី និង សុខុមាលភាពសង្គមស្ត្រីកម្ពុជា សំដៅកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងអំពើហឹង្សាលើស្ត្រី ។

## ជំពូកទី ២

## សមាសភាព

**មាត្រា ២.-**

**ក.ជ.ក.ស** មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- សម្តេចព្រះរាជអគ្គមហេសី | | ព្រះប្រធានកិត្តិយស |
| ២- នាយករដ្ឋមន្ត្រី | | អនុប្រធានកិត្តិយស |
| ៣- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | | ជាប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥- | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | ០១រូប | អនុប្រធាន |
| ៦- | រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ០១រូប | សមាជិក |
| ៧- | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ០១រូប | សមាជិក |
| ៨- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| ៩- | រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ០១រូប | សមាជិក |
| ១០- | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | ០១រូប | សមាជិក |
| ១១- | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| ១២- | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| ១៣- | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ០១រូប | សមាជិក |
| ១៤- | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| ១៥- | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| ១៦- | រដ្ឋលេខាធិការក្រសួងពត៌មាន | ០១រូប | សមាជិក |
| ១៧- | រដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| ១៨- | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ០១រូប | សមាជិក |
| ១៩- | អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | ០១រូប | សមាជិក |

**មាត្រា ៣.-**

**គ.ជ.ក.ស** មានសិទ្ធិទំនាក់ទំនងបន្ថែមជាមួយស្ថាប័ន ក្រសួងនានា អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ ប្រទេសផ្តល់ជំនួយដទៃទៀតដែលពុំបានចែងក្នុងសមាសភាពនេះ តាមការយល់ឃើញដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការ តាមការអញ្ជើញរបស់ **គ.ជ.ក.ស** ។

## ជំពូកទី ៣

## ភារកិច្ច រចនាសម្ព័ន្ធ និង ការប្រព្រឹត្តទៅរបស់ ក.ជ.ក.ស

**មាត្រា ៤.-**

**ក.ជ.ក.ស** មានភារកិច្ច ដូចតទៅ :

- ជួយរាជរដ្ឋាភិបាលក្នុងការសំរបសំរួល តាមដាន វាយតំលៃការអនុវត្តន៍ និងផ្តល់អនុសាសន៍ក្នុងគោលបំណងគាំទ្រ និងជំរុញការអនុវត្តន៍គោលនយោបាយ ច្បាប់ បទបញ្ជា និងវិធានការដែលទាក់ទងដល់ការ លើកកំពស់ស្ថានភាព តួនាទី និងសុខុមាលភាពសង្គមស្ត្រីកម្ពុជា ។

- ជួយរាជរដ្ឋាភិបាលក្នុងការតាមដានលើការអនុវត្តន៍សន្ធិសញ្ញាអន្តរជាតិនានា ពាក់ព័ន្ធទៅនឹងសិទ្ធិនារី និងលើការអនុវត្តន៍ច្បាប់ដែលទាក់ទងដល់ការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស លើបទបញ្ញត្តិច្បាប់នានាដែលមានទំនាក់ទំនងដល់ស្ថានភាពស្ត្រី ដើម្បីផ្តល់យោបល់អនុសាសន៍ ឬ សុំធ្វើវិសោធនកម្មតាមករណីជាក់ស្តែង ដើម្បីធ្វើឱ្យស្ថានភាពស្ត្រីកាន់តែប្រសើរឡើង ។

- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ជាតិ ស្តីពីការអនុវត្តន៍អនុសញ្ញា CEDAW និងស្តីពីស្ថានភាពនារី ជូនរាជរដ្ឋាភិបាលសំរេច ដើម្បីធ្វើជូនអង្គការសហប្រជាជាតិ ។

- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានបំពេញដើម្បីធ្វើជូនរាជរដ្ឋាភិបាល ។

- ពិនិត្យ និងសំរេចលើបទបញ្ជាផ្ទៃក្នុងរបស់ **ក.ជ.ក.ស**

- ទទួលភារកិច្ចផ្សេងៗទៀតតាមសំណូមពររបស់រាជរដ្ឋាភិបាល

**មាត្រា ៥.-**

**ក.ជ.ក.ស** មាន :

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅទីស្តីការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការ មានអគ្គលេខាធិការរងពីររូប និងមានបុគ្គលិកផ្ទាល់ជាអចិន្ត្រៃយ៍មួយចំនួន ដែលជាបុគ្គលិកមានស្រាប់របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។ អគ្គលេខាធិការ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៦.-**

**គ.ជ.ក.ស** អាច :

- បង្កើតអនុគណៈកម្មការជំនាញ មានសមាសភាពទាំងពីរភេទ ដែលជាមន្ត្រីមានក្របខ័ណ្ឌស្រាប់ជាជំនួយការ ដើម្បីអនុវត្តតាមតំរូវការ ភារកិច្ច ដូចដែលមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ ។
- មានទីប្រឹក្សាជាតិ និងអន្តរជាតិមួយចំនួនដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយ និង **គ.ជ.ក.ស** អគ្គលេខាធិការដ្ឋាន ។

**មាត្រា ៧.-**

**គ.ជ.ក.ស** ត្រូវជួបប្រជុំជាសាមញ្ញរៀងរាល់ត្រីមាស។ ក្នុងករណីមានការចាំបាច់ **គ.ជ.ក.ស** អាចប្រជុំជាវិសាមញ្ញតាមការកោះប្រជុំ និងក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដែលជាប្រធាន ។

ក្នុងមួយឆ្នាំម្តង **គ.ជ.ក.ស** ត្រូវធ្វើការបូកសរុបរាយការណ៍ជូនអង្គប្រជុំ **គ.ជ.ក.ស** ក្រោមព្រះរាជាធិបតីភាពរបស់សម្តេចព្រះរាជអគ្គមហេសី ព្រះប្រធានកិត្តិយស និងសម្តេចនាយករដ្ឋមន្ត្រី អនុប្រធានកិត្តិយស លើលទ្ធផលនៃការអនុវត្តន៍ លើកម្មវិធីការងារដែលត្រូវសំរបសំរួល និងអនុសាសន៍ ដែល **គ.ជ.ក.ស** ត្រូវដាក់ចេញ ។

**មាត្រា ៨.-**

**គ.ជ.ក.ស** មានបទបញ្ជាផ្ទៃក្នុង និងត្រាមួយដោយឡែករបស់ខ្លួន ។

## ជំពូកទី ៤
## ថវិកា

**មាត្រា ៩.-**

**គ.ជ.ក.ស** មានថវិកាផ្ទាល់ខ្លួនដោយឡែក ត្រូវជាឧបសម្ព័ន្ធថវិការបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។ ថវិកានេះមានប្រភពទុនពីរ :

- ថវិកាជាតិ
- ជំនួយឧបត្ថម្ភអន្តរជាតិ ប្រទេសផ្តល់អំណោយ សប្បុរសជនជាតិ ឬបរទេស ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា
មន្ត្រីក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន
ហត្ថលេខា
**មូរ សុខហួរ**

# II- ក្រុមប្រឹក្សាធម្មនុញ្ញ

## សេចក្តីសំរេច

### សេចក្តីសំរេចលេខ ០៤០/០០២/២០០១ កបធ.ច

☆☆☆

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតប្រធានរដ្ឋសភាលេខ ០៤៥ រស ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១ ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី "ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តិឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ០២ ខែមករា ឆ្នាំ ២០០១ នាសម័យប្រជុំលើកទី ៥ នីតិកាលទី ២ ហើយព្រឹទ្ធសភាក៏បានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ១៥ ខែ ឆ្នាំដដែល នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ដោយបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង គ្មានការកែប្រែអ្វីឡើយ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០១ ។
- ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ
- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ ។
- យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវប្រកាសឱ្យប្រើ ។

- យល់ឃើញថា មាត្រា ៣ វាក្យខ័ណ្ឌទី១ នៃច្បាប់នេះ បានយោងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងចង្អុល មាត្រានៃក្រមព្រហ្មទណ្ឌនេះ ចំនួនដប់ ដែលក្នុងចំណោមនោះ មាត្រា ២០៩ ៥០០ ៥០៦ និង ៥០៧ បានចែងថា : "...ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី" ។ មាត្រា ២១ នៃក្រមព្រហ្មទណ្ឌដដែលបានបញ្ជាក់ថា ".....ទោសឧក្រិដ្ឋថ្នាក់ទីបី គឺជាទោសសម្លាប់" ដូច្នេះទាំងអក្សរ ទាំងខ្លឹមសារវាក្យខ័ណ្ឌពាក់ព័ន្ធនេះ មានន័យផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដែលមាត្រា ៣២ វាក្យខ័ណ្ឌទី ២ បានចែងថា : "ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ" ។
- យល់ឃើញថា មាត្រា ៣ វាក្យខ័ណ្ឌទី ២ នៃច្បាប់នេះ បានពន្យារពេលបន្ថែម ២០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសំរាប់ឧក្រិដ្ឋកម្ម ដែលមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានកំណត់ត្រឹមតែដប់ឆ្នាំ ។ អានុភាពនៃមាត្រា ៣ វាក្យខ័ណ្ឌទី ២ នេះ បានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ជាសារវន្តមួយ : "អប្រតិសកម្មភាព នៃច្បាប់ថ្មីលើបទល្មើស ដែលបានកើតឡើងក្នុងអតីតកាល" ដែលប្រទេសកម្ពុជា ក៏ដូចជាអារ្យប្រទេសមួយចំនួន បានទទួលស្គាល់ជាទូទៅក្នុងសម័យមុនឆ្នាំ ១៩៧៥ ក៏ដូចជាសម័យក្រោយឆ្នាំ ១៩៧៨ ដោយរាប់បញ្ចូលទាំងសម័យអន្តរកាលនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផង ។ ប៉ុន្តែកម្ពុជាមិនបានបញ្ជាក់ថា គោលការណ៍ជាសារវន្តនេះ មានតម្លៃស្មើនឹងរដ្ឋធម្មនុញ្ញឡើយ ហេតុដូច្នេះហើយបានជាសភាធម្មនុញ្ញ ដែលជាអង្គការជ្រើសតាំងតាមនីតិវិធីស្របច្បាប់ និងតំណាងឱ្យប្រជារាស្ត្រពិតប្រាកដ ក្នុងការតាក់តែងរដ្ឋធម្មនុញ្ញ មិនបានបញ្ញត្តិពីគោលការណ៍នេះ ក្នុងមាត្រាណាឡើយ ក្នុងបុព្វកថាក៏មិនមានដែរ ។ លើសពីនេះទៅទៀត ទុកជាគោលការណ៍នេះ មានតម្លៃស្មើនឹងអ្វីក៏ដោយ ឬ ត្រូវបានចារិកជាលាយលក្ខអក្សរ ឬ ក៏គ្មាន ក៏គេត្រូវគោរពគោលការណ៍មួយទៀត "រាល់គោលការណ៍មានសមាសពលពីរ : វិធាន និង អញ្ញត្រកម្ម" បើវិធានមានតម្លៃស្មើអ្វី អញ្ញត្រកម្មក៏មានតម្លៃដូចគ្នា ។ អប្រតិសកម្មភាពដែលមិនត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ គេបានឃើញនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។ គោលការណ៍គ្រឹះនៃក្រមព្រហ្មទណ្ឌនេះ ក៏មានការវៀរលែងដែរ ។ មាត្រា ៦ វាក្យខ័ណ្ឌទី ២ បានចែងថា : "...ប៉ុន្តែបើច្បាប់ថ្មីនេះលុបចោលបទល្មើសណាមួយ ឬសម្រាលទោសរបស់បទល្មើសណាមួយវិញ

បទល្មើសដែលបានប្រព្រឹត្តមុនច្បាប់នេះ ត្រូវបានរួចផុតពីទោស ឬក៏ត្រូវបានសម្រាលទោសនោះតាមច្បាប់ថ្មី កុំឱ្យតែបទល្មើសនោះបានទទួលទោសជាស្ថាពររួចទៅហើយ" ។ ត្រង់នេះច្បាប់ថ្មីដែលយើងកំពុងពិនិត្យបានបំពេញល័ក្ខខ័ណ្ឌបានដោយបរិបូរណ៌ ។ មាត្រា ៣៨ និង ៣៩ បានបន្ថយទោសប្រហារជីវិត មកត្រឹមតែទោសជាប់គុកអស់មួយជីវិតតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតទោសជាប់គុកដោយបង្ខំឱ្យធ្វើការជាទម្ងន់ (Travaux forcés) ឬទោសដាក់គុកបង្ខំឱ្យធ្វើការ និងបង្ខាំងមិនឱ្យចេញ (réclusion) មកត្រឹមតែទោសជាប់គុកធម្មតា (emprisonnement)។ សារណាអំណោយផលមួយទៀត គឺការគោរពល័ក្ខខ័ណ្ឌចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ ទន្ទឹមនឹងលក្ខណៈចរិតពិសេសនៃករណី ។ មាត្រាមួយនៃច្បាប់នេះ បានបន្ថែមល័ក្ខខ័ណ្ឌបណ្ដឹង ជាវត្ថុធាតុគូបផ្សំបទល្មើស (éléments constitutifs de l'infraction) ច្រើនទៀតទៅលើល័ក្ខខ័ណ្ឌជាទម្លាប់ ដែលមានស្រាប់នៅក្នុងមាត្រាទាំងឡាយ ដែលគេចង្អុលក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។ ល័ក្ខខ័ណ្ឌបន្ថែមទាំងនោះគឺ :

- ចំពោះពិរុទ្ធជន មានតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត
- ចំពោះបទល្មើសកំរិតត្រឹមឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ
- ចំពោះវេរៈវេលា កំរិតត្រឹមអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ។

រួមសេចក្ដីទៅ មិនមានឃើញអ្វីប៉ះពាល់ដល់ធម្មនុញ្ញភាពទេ ។

- យល់ឃើញថា មាត្រា ៩ ដល់មាត្រា ៣២ ដែលបានបញ្ញត្តិពីសមាសភាពចៅក្រមជំនុំជម្រះ ការតែងតាំង ការសំរេចសេចក្ដី សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ប្រធាន អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកជំនួយការផ្សេងៗ មានភាគីខ្មែរ និងភាគីមកពីអង្គការសហប្រជាជាតិ ដូចមានតារាងសំយោគខាងក្រោមនេះ :

| សមាសភាព | សាលាដំបូង | សាលាឧទ្ធរណ៍ | តុលាការកំពូល | ការិយាល័យរដ្ឋបាល |
|---|---|---|---|---|
| ១-ចៅក្រមជម្រះក្តី | | | | |
| -ខ្មែរ (ប្រធាន) | ៣ | ៤ | ៥ | |
| -អ.ស.ប | ២ | ៣ | ៤ | |
| **សរុប** | ៥ | ៧ | ៩ | |
| ២-សម្លេងអប្បបរមាក្នុងការសំរេច | ៤ | ៥ | ៦ | |
| ៣-សហព្រះរាជអាជ្ញា | | | | |
| -ខ្មែរ | ១ | ១ | ១ | |
| -អ.ស.ប | ១ | ១ | ១ | |
| **សរុប** | ២ | ២ | ២ | |
| ៤-សហចៅក្រមស៊ើបអង្កេត | | | | |
| -ខ្មែរ | ១ | ១ | ១ | |
| -អ.ស.ប | ១ | ១ | ១ | |
| **សរុប** | ២ | ២ | ២ | |
| ៥-ការិយាល័យរដ្ឋបាល | | | | |
| -ខ្មែរ (ប្រធាន) | | | ១ | |
| -អ.ស.ប (អនុប្រធាន) | | | ១ | |
| **សរុប** | | | ២ | |

ដើម្បីបំរើការអង្គជំនុំជម្រះវិសាមញ្ញនេះ ទាំងភាគីខ្មែរ ទាំងភាគីមកពីអង្គការសហប្រជាជាតិ សុទ្ធតែត្រូវបានតែងតាំងឡើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នកំពូលជាតិខ្មែរសុទ្ធសាធ សូម្បីតែប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល ក៏ត្រូវបានតែងតាំងដោយអាជ្ញាធរកម្ពុជាដែរ ។

អង្គការសហប្រជាជាតិ មានភារកិច្ចត្រឹមស្នើបញ្ជីបេក្ខជនតែប៉ុណ្ណោះ ហើយគ្មានសិទ្ធិសម្រេចទេ ។ គេមិនឃើញមានមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ហាមឃាត់មិនឱ្យស្ថាប័នជាតិ ជាពិសេសឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម តែងតាំងជនមកពីអង្គការសហប្រជាជាតិ ដែលកម្ពុជាជាសមាជិកដែរនោះទេ ។ បើនិយាយឱ្យអស់ទៅ ក្នុងឋានៈខ្លួនជាអង្គការប្រមូលផ្តុំប្រជាជាតិស្ទើរតែទាំងអស់ក្នុងពិភពលោក អង្គការសហប្រជាជាតិអាចឧទ្ទេសនាមបេក្ខជនគ្រប់សញ្ជាតិ រួមមានទាំងខ្មែរ ឬ ខ្មែរមានសញ្ជាតិពីរផង ។ គ្រប់លំដាប់ថ្នាក់នៃអង្គជំនុំជម្រះក្តី ៖ សាលាដំបូង សាលាឧទ្ធរណ៍ តុលាការកំពូល ភាគីខ្មែរសុទ្ធតែមានចំនួនភាគច្រើន ហើយសុទ្ធតែខ្មែរទៀតដែលត្រូវបានទទួលឋានៈជាប្រធាន ។ ប៉ុន្តែចំនួនសំលេងអប្បបរមាក្នុងសេចក្តីសម្រេច ដែលមានកំពស់ខ្ពស់ ជាយន្តការតុល្យការមួយ ធ្វើឱ្យមានសមធានាខាងផ្លូវយុត្តិធម៌ ព្រោះភាគីទាំងពីរចាំបាច់ត្រូវតែសហការគ្នាដោយខានមិនបាន ។ ការយកប្រព័ន្ធតុលាការកម្ពុជា ដែលមានស្រាប់ និងការរើសយករាជធានីភ្នំពេញជាទីតាំងដំណើរការ ជាការគាំពារថ្មីមួយទៀតដល់អធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនេះ បានយោងច្បាប់ចំនួនប្រាំមួយ ដែលមានចែងក្នុងមាត្រា ៣ ៤ ៥ ៦ ៧ និង ៨ ។ ក្នុងចំណោមនេះប្រាំទៅហើយ (ប្រាំចុងក្រោយ) ដែលសុទ្ធជាអនុសញ្ញាអន្តរជាតិ ។ ដូច្នេះការទាមទារឱ្យមានការរួមចំណែកពីសំណាក់អង្គការសហប្រជាជាតិ ជាការចាំបាច់

- យល់ឃើញថា មាត្រា ៤០ ដែលហាមឃាត់មិនឱ្យរាជរដ្ឋាភិបាលកម្ពុជា ស្នើសុំឱ្យមានការលើកលែងទោស ឬ ការអនុគ្រោះទោស មិនមានធ្វើឱ្យប៉ះពាល់ដល់ធម្មនុញ្ញភាពទេ ពីព្រោះមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិពីព្រះមហាក្សត្រ មិនមែនពីរាជរដ្ឋាភិបាលឡើយ ។ មាត្រានេះចែងថា "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស"

## សំរេច

**មាត្រា ១ ..**

ផ្អែកតាមមូលបទខាងលើ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០០១ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទបញ្ញត្តិទាំងឡាយដែលបានចែងថា "...ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី" ដែលជាទោសសម្លាប់ ក្នុងមាត្រា ២០៩ ៥០០ ៥០៦ និង ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ ។

**មាត្រា ២ .-**

សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្ដីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**ចាន់ សុក**

# III- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ១៦ អនក្រ.បក

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការពារជាតិ
~~~

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ .-**

ត្រូវបានបង្កើត វិទ្យាស្ថានយោធាកម្ពុជា ដែលមានស្ថាប័នចំណុះមួយចំនួនរួមមាន :

- មជ្ឈមណ្ឌលហ្វឹកហ្វឺនយុទ្ធសាស្ត្រយោធា
- មជ្ឈមណ្ឌលហ្វឹកហ្វឺនបញ្ជាការ និងសេនាធិការ
- មជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាបរទេស និងចំណេះទូទៅ

**មាត្រា ២ .-**

វិទ្យាស្ថានយោធាកម្ពុជា ជាមជ្ឈមណ្ឌលហ្វឹកហ្វឺន ចំណុះឱ្យក្រសួងការពារជាតិ មានភារកិច្ចដឹកនាំ និងគ្រប់គ្រង ហ្វឹកហ្វឺន បណ្តុះបណ្តាល បំប៉ននាយទាហាននៃកងទ័ពទាំងបីប្រភេទ ចាប់ពីថ្នាក់មេបញ្ជាការកងវរសេនាតូច និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។ ហ្វឹកហាត់អំពីការងារយុទ្ធវិធី-យុទ្ធសាស្ត្រយោធា ការងារបញ្ជាការ-សេនាធិការ ចំប៉ននាយទាហានជាន់ខ្ពស់ និងវិន័យ សណ្តាប់ធ្នាប់ បទបញ្ជាផ្ទៃក្នុង ជូរកងទ័ពភាសាបរទេស ព្រមទាំងចំណេះទូទៅសមស្របទៅតាមសភាពការណ៍រីកចំរើនរបស់មាតុភូមិ និងការរីកចំរើនរបស់កងយោធពលខេមរភូមិន្ទ ។ ក្រៅពីភារកិច្ចខាងលើ វិទ្យាស្ថានយោធាកម្ពុជា ត្រូវបានទទួលភារកិច្ចបន្ថែមទៀត តាមការប្រគល់ភារកិច្ចរបស់ក្រសួងការពារជាតិ ។

**មាត្រា ៣ .-**

រចនាសម្ព័ន្ធ និងក្របខ័ណ្ឌរបស់វិទ្យាស្ថានយោធាកម្ពុជា មាននៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៤ ._**

ការរៀបចំរចនាសម័ន្ធចាត់តាំង និងក្របខ័ណ្ឌរបស់វិទ្យាស្ថានយោធាកម្ពុជា ចាប់ពីថ្នាក់ក្រោមមជ្ឈមណ្ឌលចុះ ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៥ ._**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័យ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៧ ._**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

**<u>សច្ចាប័ន</u> :**

ភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

យល់ព្រម និង ឯកភាព

លើរចនាសម័ន្ធចាត់តាំង វិទ្យាស្ថានយោធាកម្ពុជា

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

## រចនាសម្ព័ន្ធចាត់តាំង
## វិទ្យាស្ថានយោធាកម្ពុជា




## អនុក្រឹត្យលេខ ១៧ អនក្រ.បក
## ស្តីពីការ
## បង្កើតសង្កាត់កោះរ៉ុង ចំណុះខណ្ឌមិត្តភាព ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-**

ត្រូវបានបង្កើតសង្កាត់កោះរ៉ុង ចំណុះខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដោយកាត់យកភូមិសាស្ត្រមួយចំនួនរបស់សង្កាត់លេខ ៣ ក្នុងខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**មាត្រា ២ .-**

សង្កាត់កោះរ៉ុង មានព្រំប្រទល់រដ្ឋបាល :

- ខាងជើង ទល់នឹងសមុទ្រ ស្រុកបូទុមសាគរ ខេត្តកោះកុង
- ខាងកើត ទល់នឹងសមុទ្រ សង្កាត់លេខ ៣ ខ័ណ្ឌមិត្តភាព
- ខាងលិច ទល់នឹងសមុទ្រ ស្រុកគីរីសាគរ ខេត្តកោះកុង
- ខាងត្បូង ទល់នឹងសមុទ្រ

**មាត្រា ៣ .-**

ទីតាំងរដ្ឋបាលសង្កាត់កោះរ៉ុង ស្ថិតនៅក្នុងភូមិដើមថ្កូវ ។

**មាត្រា ៤ .-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ១៨ អនក្រ.បក
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការតំរង់ទិសអន្តរក្រសួង ដើម្បីដឹកនាំដំណើរការនៃគំរោងការជំនួយបច្ចេកទេស ទាក់ទងនឹងគោលនយោបាយពាណិជ្ជកម្ម
## រាជរដ្ឋាភិបាល

====

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១ .-**

បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ តំរង់ទិសអន្តរក្រសួង (Inter-Minisrial Steering Committee) មួយដើម្បីកសាងឯកសារ និងគ្រប់គ្រងនូវសេចក្ដីត្រូវការ គំរោងការជំនួយបច្ចេកទេសរបស់បណ្ដាក្រសួងទាំងឡាយដែលពាក់ព័ន្ធ សំរាប់បំរើឱ្យផ្នែកពាណិជ្ជកម្ម និងផ្នែកពាក់ព័ន្ធដល់គោលនយោបាយពាណិជ្ជកម្ម ។

**មាត្រា ២ .-**

គណៈកម្មាធិការនេះ មានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន

| | | | |
|---|---|---|---|
| ២-ឯកឧត្តម | **ឈៀង យ៉ាណារ៉ា** | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តម | **ម៉ែន សុម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយ និងរដ្ឋាករ | អនុប្រធាន |
| ៤-ឯកឧត្តម | **សៀង ឡាប្រេស្ស** | អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥-ឯកឧត្តម | **ហ៊ុល លីម** | អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦-ឯកឧត្តម | **សារ៉ាក់ ខាន់** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៧-ឯកឧត្តម | **ឡុង វ៉ាន់ហាន** | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៨-ឯកឧត្តម | **ឈុន សារ៉េត** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៩-ឯកឧត្តម | **ភូ លីវឌ្ឍ** | អគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា | សមាជិក |
| ១០-លោកជំទាវ | **តាល់ ណែមអ៊ីម** | អគ្គនាយកធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១១-លោក | **សុខ សុភ័ត្រ** | ប្រធាននាយកដ្ឋាន អាស៊ាននិងអង្គការអន្តរជាតិ | សមាជិក |

**មាត្រា ៣ .-**

គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ :

១- រៀបចំប្រមូលផ្តុំ ចងក្រងឯកសារផ្លូវការនូវរាល់សេចក្តីត្រូវការជំនួយបច្ចេកទេស របស់ក្រសួងនីមួយៗ ដើម្បីសរុបលើកសំណើសុំជំនួយបច្ចេកទេសពីអង្គការសំខាន់ៗទាំងប្រាំមួយរួមមានអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារពិភពលោក (WB) កម្មវិធី

អភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អង្គសន្និសិទរបស់អង្គការសហប្រជាជាតិស្ដីអំពីពាណិជ្ជកម្ម និងអភិវឌ្ឍន៍ (UNCTAD) អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ក៏ដូចជាសុំជំនួយបច្ចេកទេស ពីបណ្ដាប្រទេសរីកចំរើនទានានាក្នុងពិភពលោកជាលក្ខណៈទ្វេភាគី ។

២- ធ្វើការណែនាំដល់ក្រសួងពាក់ព័ន្ធ ឱ្យចេះកសាងឯកសារគំរោងការជំនួយបច្ចេកទេសសំរាប់រៀបចំគោលនយោបាយ និងអភិវឌ្ឍន៍របស់សាមុីក្រសួងនីមួយៗ ដើម្បីយកមកប្រមូលផ្ដុំចងក្រងជាឯកសារផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់សុំជំនួយបច្ចេកទេស ។

៣- គណៈកម្មាធិការត្រូវធ្វើការសំរបសំរួលជាប្រចាំ ជាមួយតំណាងអង្គការសំខាន់ៗទាំងប្រាំមួយដូចមានចែងក្នុងចំណុចទី ១ នៃមាត្រា ៣ ដើម្បីបើកកិច្ចប្រជុំតុមូលក្នុងស្រុកមួយរវាងអន្តរក្រសួង សំដៅកសាងឱ្យបានឯកសារ ស្ដីពីសេចក្ដីត្រូវការជំនួយបច្ចេកទេសពាក់ព័ន្ធនឹងគោលនយោបាយ ពាណិជ្ជកម្មដ៏សុក្រិត្យមួយ ដើម្បីផ្ញើជូនទៅអង្គការទាំងប្រាំមួយ ។

៤- គណៈកម្មាធិការនេះ មានភារកិច្ចត្រួតពិនិត្យមើលនូវជំនួយបច្ចេកទេសដែលទទួលបានដោយក្រសួងនីមួយៗតាមរយៈទ្វេភាគី ឬពហុភាគី ដោយធ្វើយ៉ាងណាជៀសវាងកុំឱ្យមានការទទួលជំនួយនោះ ត្រួតគ្នា ។

៥- តាមដានត្រួតពិនិត្យ និងធ្វើការណែនាំជាប្រចាំនូវការប្រើប្រាស់ជំនួយបច្ចេកទេសរបស់ក្រសួងនីមួយៗ ហើយត្រូវធ្វើសេចក្ដីរាយការណ៍ ឱ្យបានទៀងទាត់នូវប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយបច្ចេកទេស ដែលទទួលបានជូនទៅគណៈរដ្ឋមន្ត្រី ។ ក្នុងករណីទំហំការងារនោះហួសសមត្ថកិច្ចរបស់ខ្លួន គណៈកម្មាធិការត្រូវរាយការណ៍ សុំយោបល់ និងសេចក្ដីសំរេចពីរាជរដ្ឋាភិបាល ។

**មាត្រា ៤ .-**

គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញមន្ត្រីថ្នាក់ខ្ពស់ពីក្រសួងពាក់ព័ន្ធ ឱ្យចូលរួមប្រជុំគណៈកម្មាធិការ ប្រសិនជាយល់ឃើញថាករណីចាំបាច់ ។

**មាត្រា ៥ .-**

គណៈកម្មាធិការត្រូវជ្រើសតាំង មន្ត្រីជាន់ខ្ពស់របស់ខ្លួនដើម្បីធ្វើជា Focal Point សំរាប់ទំនាក់ទំនងជាមួយអង្គការសំខាន់ៗទាំងប្រាំមួយ ។ គណៈកម្មាធិការអាចប្រើប្រាស់ នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្មធ្វើជាសេនាធិការ និងជាយន្តការសំរាប់ការងារប្រចាំថ្ងៃរបស់ខ្លួន ។

**មាត្រា ៦ .-**

សមាជិកគណៈកម្មាធិការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន។

**មាត្រា ៧ .-**

គណៈកម្មាធិការមានសិទ្ធិបង្កើតក្រុមការងារតូចៗ ដើម្បីកសាងជំនួយបច្ចេកទេសទៅតាមផ្នែកពាក់ព័ន្ធនីមួយៗ ប្រសិនជាយល់ឃើញថាចាំបាច់ ។ ប្រធាន និង សមាសភាពសមាជិកក្រុមការងារអាស្រ័យលើគណៈកម្មាធិការជាអ្នកសំរេច ។

**មាត្រា ៨ .-**

គណៈកម្មាធិការនេះ ត្រូវមានខ្ទង់ថវិកាដោយឡែកមួយ ដែលជាឧបសម្ព័ន្ធនៃថវិកាក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គទេសាភិបាលធនាគារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៦៩ អនក្រ.តត
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណូមពរចាំបាច់

**សំរេច**

**មាត្រា ១ .-**

ត្រូវបានបំពាក់ **មេដាយមាសស្ថានាជាតិ** ជូនឯកឧត្ដម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដែលបានចំណាយថវិកាជាច្រើន ដើម្បីជួយស្ថាបនាផ្លូវលំមួយខ្សែក្នុងស្រុកសំរោង ខេត្តតាកែវ ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៧០ អនក្រ.តត
## ស្តីពីការជូនមេដាយសុវត្ថារា

≈≈≈

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១ .-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ "**ធិបឌិន្ទ**" ជូនឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្មចំនួន ០២រូប ដែលបានយកអស់កម្លាំងកាយ កម្លាំងចិត្ត ខិតខំបំពេញភារកិច្ច អនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល លើវិស័យពាណិជ្ជកម្ម ហើយទទួលបានស្នាដៃល្អ ដូចមានរាយនាមខាងក្រោមនេះ :

១- ឯកឧត្តម **គីម ស៊ីថន**

២- ឯកឧត្តម **កែវ សុខែណ**

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ៧១ អនក្រ.តត
# ស្តីពីការដកហូតមុខតំណែងមន្ត្រីរាជការ

≈≈≈

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-**

ត្រូវបានដកហូតមុខតំណែងលោក **យ៉ែន គឹមហ្សិរ** ពីអភិបាលស្រុកកូនមុំ ខេត្តរតនគិរី ឱ្យមកបំរើការងារនៅសាលាខេត្តរតនគិរីវិញ ។

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អភិបាលខេត្តរតនគិរី និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**